**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ០១/១០-ខិននីតិច

កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា៣១៧នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: លី តៃសេង

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: ទូន ស៊ីផាន់

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ខិននីតិច អ៊ិនធើណេសិនណល (ខេមបូឌា) ខូ អិលធីឌី

អាសយដ្ឋាន : ភូមិព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៨៩ ៨៦៣ ១៨១ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ជាតិ ខេមរា មន្ត្រី GMAC

២- លោកស្រី សួរ វ៉ាន់ធី បុគ្គលិករដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពយុវជនខ្មែរ

- សហជីពយុវជនខ្មែរ នៃក្រុមហ៊ុន ខិននីតិច

អាសយដ្ឋាន : ភូមិព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៦១២ ៦៦១ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: អវត្តមាន

ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ៨៨១ ៨២៤

House No. 72, Corner 592 and 327, Sangkat Boeng Kak II, Khan Tuol Kork, Phnom Penh Cambodia • Tel/Fax: 023 881 824

Email: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើរយៈពេលខ្លីៗ ពី ៣ ថ្ងៃទៅដល់ ៥ ថ្ងៃ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល១០០ភាគរយ រួមទាំងអត្ថប្រយោជន៍ផ្សេងៗ និងសងវិលឹកឡើងវិញ។ ដោយឡែកភាគីក្រុមហ៊ុនផ្តល់ជូន៥០ភាគរយពេលគ្មានការងារធ្វើ ដោយក្រុមហ៊ុនអនុវត្តតាមកំណត់ហេតុ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ រវាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត។

២- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់បាយមួយពេល ឬលុយចំនួន ៤០០០ រៀល ជូនកម្មករនិយោជិតដែលក្រុមហ៊ុនតំរូវឱ្យធ្វើការថែមម៉ោងថ្ងៃបុណ្យ ឬថ្ងៃអាទិត្យ (ព្រោះកន្លងមកអត់ដែលឱ្យសោះ ទោះបី ១០០០ រៀលក៏ដោយ)។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ឱ្យបានទេ ដោយហេតុថា កម្មករនិយោជិតដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃបុណ្យ ឬថ្ងៃអាទិត្យ ធ្វើការត្រឹមតែប្រាំបីម៉ោងប៉ុណ្ណោះ។

៣- នៅពេលក្រុមហ៊ុនឱ្យកម្មករនិយោជិតធ្វើការថែមម៉ោង សុំឱ្យក្រុមហ៊ុនរៀបចំមធ្យោបាយជូនកម្មករដល់ផ្ទះដោយសុវត្ថិភាព ពុំនោះទេ សុំឱ្យក្រុមហ៊ុនចេញថ្លៃចំណាយក្នុងការធ្វើដំណើរតាមការជាក់ស្តែងជូនកម្មករ ដោយឡែកភាគីក្រុមហ៊ុនមិនអាចរៀបចំមធ្យោបាយជូនឡើយ ដោយហេតុថា ជាការងារវេន គឺវេនយប់ និងវេនថ្ងៃ ហើយក្រុមហ៊ុនអនុវត្តមកមិនដែលមានបញ្ហាឡើយ ដោយសារកម្មករនិយោជិតស្ម័គ្រចិត្តសហការការងារជាមួយក្រុមហ៊ុន ។

៤- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនរៀបកៅអីឱ្យកម្មករកាត់ព្រុយបានអង្គុយ (អង្គុយរហូត) ដូចកម្មករផ្នែកផ្សេងៗទៀត។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចដាក់ជូនបានទេ គឺសុំអនុវត្តតាមប្រកាសរបស់នាយកដ្ឋានពេទ្យការងារ ។

៥- នៅពេលកម្មការិនីសុំច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ៩០ ថ្ងៃ ហើយវិលមកវិញមានសុខភាពមិនប្រក្រតី សុំឱ្យក្រុមហ៊ុនអនុញ្ញាសុំច្បាប់ជាបន្តទៀត តាមការជាក់ស្តែង ដោយការឈប់សម្រាកចំនួន ៩០ ថ្ងៃនេះ មិនរាប់បញ្ចូលថ្ងៃបុណ្យ និងថ្ងៃអាទិត្យឡើយ។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមច្បាប់ស្តីពីការងារពោលគឺ ចំនួន ៩០ ថ្ងៃពេញ ។

៦- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថមដល់កម្មករផ្នែកឃ្លាំង ក្នុងមួយនាក់ចំនួន ១០ ដុល្លា ព្រោះកម្មករផ្នែកឃ្លាំងធ្វើការច្រើនជាងផ្នែកផ្សេងៗ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារនេះបានឡើយ ។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០០៧ ក.ប/អក/វ.ក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៩ ទាមទារឱ្យកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រី ជំនាញធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្ត បន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៦ ចំណុចលើការទាមទារចំនួន១២ចំណុច ។ ចំណុចមិនសះជាចំនួន០៦ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ តាមរបាយការណ៍ស្តីពីវិវាទការងាររួមមិនសះជាលេខ ០០៧ ក.ប/អក/វ.ក ចុះថ្ងៃ ទី០៦ ខែមករា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០៦ចំណុចនេះ នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០ (វេលាម៉ោង ០២:០០ នាទី រសៀល) ។ ប៉ុន្តែ ភាគីកម្មករនិយោជិតអវត្តមាន ដោយគ្មានមូលហេតុ ចំណែកឯភាគីនិយោជកវិញបានអញ្ជើញមកចូលរួមតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ខិននីតិច ជូនលោកស្រី សួរ វ៉ាន់ធី ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ ២០១០ ។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខិននីតិច ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០០៨ ។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខិននីតិច ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០០ ។

៤- លក្ខន្តិកៈក្រុមហ៊ុន ខិននីតិច ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០២ ។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខិននីតិច ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ។

៦- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរលេខ ៧៤៧ សសយខ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ គោរព ជូនលោកនាយកក្រុមហ៊ុន ខិននីតិច ស្តីពីការសុំជួបពិភាក្សា និងសម្រុះសម្រួលនូវករណីវិវាទការងារ របស់កម្មករនិយោជិត ។

៧- លិខិតពឹងពាក់ដោយអាណត្តិ និងជួយអមក្នុងការសម្របសម្រួលជាមួយក្រុមហ៊ុន របស់កម្មករ និយោជិតក្រុមហ៊ុន ខិននីតិច គោរពជូនលោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០០៩ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខិននីតិច លេខ ០០៧ ក.ប/អក/វក ចុះ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ខិននីតិខ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤២ កប/អក/វក/លកអ ចុះថ្ងៃទី២១ ខែ មករា ឆ្នាំ២០១០ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤៣ កប/អក/វក/លកអ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ ។

THE ARBITRATION COUNCIL

៣- លិខិតអញ្ជើញលោកប្រធានសហជីពយុវជនខ្មែរ នៃក្រុមហ៊ុន ខិននីតិច ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល លេខ ០១៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០។

៤- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីព កម្មករនិយោជិត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

**ការរកឃើញអង្គហេតុ:**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុទាក់ទងនឹងការទាមទារទាំងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិតអវត្តមាននៅថ្ងៃសវនាការ ដោយមិនបានផ្តល់មូលហេតុណាមួយឡើយ។

**ហេតុផលក្នុងការធ្វើសេចក្តីសម្រេច:**

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ " *ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់* " ។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ចែងថា " *ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន* " ។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់លេខ ៣០/០៥-មូរៀ. លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉ៃ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន និងលេខ ០៩/០៩-នីមបឹស ធិចផាឡូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញមុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ។

THE ARBITRATION COUNCIL

លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺ ភាគីមិនបានផ្តល់មូលហេតុសម្រាប់ការមិនបង្ហាញខ្លួន។

ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការទៅកាន់ភាគីទាំងពីរ។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងដោយនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃថ្ងៃសវនាការតាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២: ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ "* ។

បន្ថែមពីនេះទៀត ប្រការ ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"* ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង (ដូចជាខាងសហព័ន្ធសហជីព ឬមេធាវី) ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣: ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតអវត្តមាន និងមិនបានផ្តល់មូលហេតុត្រឹមត្រូវអ្វីទាំងអស់ដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីការមិនចូលរួមសវនាការនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ០១/១០-ខិននីតិច នេះ ដោយភាគីកម្មករនិយោជិតមិនមានវត្តមាន នៅពេលសវនាការ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង និងអង្គច្បាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ:

## សម្រេច និង បង្គាប់

បិទសំណុំរឿងលេខ ០១/១០-ខិននីតិច ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : លី តៃសេង

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : ទួន ស៊ីផាន់

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : ម៉ែន ម៉ុនឈរា

ហត្ថលេខា: ------------------------------